# សេចក្តីប្រកាសព័ត៌មាន
# សិក្ខាសាលាថ្នាក់ជាតិស្តីពីការត្រៀមទទួលការវាយតម្លៃអញ្ញមញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ កិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦

នាព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា មានប្រារព្ធពិធីបើកសិក្ខាសាលាថ្នាក់ជាតិស្តីពីការត្រៀមទទួលការវាយតម្លៃអញ្ញមញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **កិត្តិសេដ្ឋាបណ្ឌិត គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឯកឧត្តម **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងលោក Alassane Sow តំណាងធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា ។

សិក្ខាសាលាថ្នាក់ជាតិនេះត្រូវបានរៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សហការជាមួយធនាគារពិភពលោកនិងមានរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ក្នុងគោលបំណងបង្កើនការយល់ដឹងឲ្យកាន់តែច្បាស់អំពីកិច្ចដំណើរការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation) បទដ្ឋានអន្តរជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដល់សិក្ខាកាមមកពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីអនុវត្តច្បាប់ តុលាការ និងតំណាងវិស័យឯកជន សរុបចំនួន ១៥០រូប ។

ថ្លែងនៅក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិនេះ ឯកឧត្តម **ជា ចាន់តូ** បានជម្រាបជូនអង្គសិក្ខាសាលាអំពីភាពរីកចម្រើនរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាលើទំហំប្រតិបត្តិការនិងជំនាញ បន្ទាប់ពីមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជា ដែលបច្ចុប្បន្ន អង្គភាពនេះបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូនៅក្នុងតំបន់និងអន្តរជាតិ ។ ទន្ទឹមនឹងនេះ ដោយមានកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏បានចូលជាសមាជិករបស់ក្រុម Egmont និងត្រូវបានបំពាក់ប្រព័ន្ធបច្ចេកវិទ្យា សម្រាប់រាយការណ៍ប្រតិបត្តិការជាអេឡិចត្រូនិកដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងកំពុងបន្តពង្រីកវិសាលភាព ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុផ្សេងទៀត ដើម្បីធ្វើឲ្យការងារទប់ស្កាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់។

បន្ទាប់មក ជាកិច្ចចាប់ផ្តើមបើកសិក្ខាសាលា **កិត្តិសេដ្ឋាបណ្ឌិត គាត ឈន់** បានជម្រាបជូនអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលសម្រេចបានសមិទ្ធផលការងារធំៗជាច្រើន ជូនជាតិនិងមាតុភូមិ ក្នុងការពង្រឹងក្របខ័ណ្ឌច្បាប់និងយន្តការអនុវត្តច្បាប់ ដូចជាបានបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់

ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានដាក់ឲ្យប្រើប្រាស់នូវយុទ្ធសាស្ត្រជាតិរយៈពេល៥ឆ្នាំ និងបានបំពេញបន្ថែមនូវវិធានការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុក នៃយុទ្ធសាស្ត្រនេះ ធ្វើវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដាក់ឲ្យប្រើប្រាស់អនុក្រឹត្យស្តីពីការបង្កកទ្រព្យរបស់ភេរវករនិងអង្គការនានា និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ ដើម្បីកសាងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដ៏រឹងមាំមួយនៅកម្ពុជា ខណៈដែលកម្ពុជាកំពុងធ្វើសមាហរណកម្មក្នុងតំបន់និងពិភពលោក ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ** ក៏បានជម្រាបជូនអំពីកិច្ចដំណើរការវាយតម្លៃអញ្ញមញ្ញរបស់ APG នៅដំណាច់ឆ្នាំ២០១៦ និងការបង្កើតក្រុមការងារអន្តរក្រសួងត្រៀមទទួលការវាយតម្លៃនេះ និងបានស្នើឲ្យថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធផ្តល់ការគាំទ្រទាំងស្មារតីនិងធនធាន និងជួយជំរុញដល់សមាជិកក្រុមការងារមកពីក្រសួង-ស្ថាប័នរៀងៗខ្លួន ដើម្បីអនុវត្តការងារនេះឲ្យទទួលបានជោគជ័យ ។